# សម្ព័ន្ធអង្គការសង្គមស៊ីវិលអំពាវនាវឲ្យមានការផ្តល់ហេតុផលបន្ថែម លើការដំឡើងឋានៈដល់អគ្គនាយកទូរគមនាគមន៍កម្ពុជា

***ភ្នំពេញ ថ្ងៃទី១៩ មិនា ២០១៣***- ការដំឡើងឋានៈដល់មន្ត្រីរាជការដែលកំពុងស្ថិតនៅក្រោមការស៊ើបអង្កេតពីបទពាក់ព័ន្ធនឹងការប្រព្រឹត្តិមិនប្រក្រតី និងជាប់សង្ស័យពីបទគៃបន្លំ និងការប្រព្រឹត្តិអំពើពុករលួយគឺជាគំរូមិនល្អសម្រាប់សង្គមកម្ពុជា។

យោងតាមរបាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយចេញផ្សាយនៅថ្ងៃនេះ និងកាលពីម្សិលមិញ បានបង្ហាញថា អតីតអគ្គនាយកទូរគមនាគមន៍កម្ពុជាដែលជាសហគ្រាសសាធារណៈ ត្រូវបានតែងតាំងជាអនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បន្ទាប់ពីលោកត្រូវបានចោទប្រកាន់ដោយបុគ្គលិកពីបទគៃបន្លំ និងពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងារ។ កាលពី ថ្ងៃទី១៣ ខែ កុម្ភៈ ឆ្នាំ២០១៣ បុគ្គលិកជាង២០០នាក់បានធ្វើតវ៉ាទាមទារដកលោក ឡៅ សារឿន ពីមុខតំណែង។

អង្គភាពប្រឆាំងអំពើពុករលួយ ត្រូវបានស្នើសុំឲ្យធ្វើការស៊ើបអង្កេតស៊ីជម្រៅពាក់ព័ន្ធនឹងករណីនេះ។ បន្ទាប់មក ឯកឧត្តម ឱម យ៉ិនទៀង ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ និងឯកឧត្តម សូរ ឃុន រដ្ឋមន្ត្រីក្រសួងប្រៃសនីយ៍ និងទូរគមនាគមន៍បានជួបជាមួយបុគ្គលិកទូរគមនាគមន៍កម្ពុជា និងលើកទឹកចិត្តដល់ពួកគេឲ្យដាក់ពាក្យបណ្តឹងដោយបើកចំហរ និងបង្ហាញភស្តុតាង នេះបើយោងតាមអត្ថបទសារព័តមាន ចេញផ្សាយដោយភ្នំពេញប៉ុស្តិ៍កាលពីខែកុម្ភៈ ឆ្នាំ២០១៣កន្លងមក។

សេចក្តីប្រកាសដំឡើងឋានៈ លោក ឡៅ សារឿន ជាអនុរដ្ឋលេខាធិការនៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កាលពីម្សិលមិញ បានធ្វើឲ្យមានការភ្ញាក់ផ្អើលដល់សាធារណៈជនកម្ពុជា។ អង្គភាពប្រឆាំងអំពើពុករលួយបានបដិសេធអត្ថាធិប្បាយជុំវិញករណីនេះ ហើយក៏មិនមានការបង្ហាញណាមួយថាតើការស៊ើបអង្កេតត្រូវបានបញ្ចប់ ហើយការស៊ើបអង្កេតទទួលបានលទ្ធផលយ៉ាងណានោះទេ។

តាមការអនុវត្តជាទូទៅ បុគ្គលណាដែលស្ថិតនៅក្រោមការស៊ើបអង្កេតនៃការចោទប្រកាន់ពីបទប្រព្រឹត្តិអំពើពុករលួយ ឬការប្រព្រឹត្តិមិនប្រក្រតីនឹងត្រូវព្យួរពីមុខតំណែងបច្ចុប្បន្ន ហើយមិនអាចត្រូវបានផ្តល់ការងារ ឬដំឡើងឋានៈលុះត្រាណាករណីចោទប្រកាន់នោះត្រូវបានដោះស្រាយរួចរាល់ជាស្ថាពរ។ ដោយសារមិនមានការអត្ថាធិប្បាយណាមួយជុំវិញការស៊ើបអង្កេត និងលទ្ធផលនៃការស៊ើបអង្កេតពីអង្គភាពប្រឆាំងអំពើពុករលួយ ករណីនេះបានធ្វើឲ្យមានមន្ទិលសង្ស័យ និងសំណួរថាតើករណីនេះត្រូវបានដោះស្រាយដោយសមស្រប ឬយ៉ាងណានោះទេ។ តាមការយល់ឃើញរបស់សាធារណៈជន ករណីនេះហាក់ដូចជាទម្លាប់មួយមិនសមស្របក្នុងការដំឡើងតំណែងដល់មន្ត្រីរាជការ ដែលកំពុងត្រូវបានចោទប្រកាន់ដោយបុគ្គលិកជាង២០០នាក់ពីបទគៃបន្លំ និងពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងារ។

**Contact:**
Transparency International Cambodia, Mr Kol PREAP, Email: kolpreap@ticambodia.org, Phone (+855) 012 877 833
CISA, Mr. Yong Kim Eng, Vice Chair Email: cisacoordinator@saatsaam.info, Phone (+855) 016 828 211
CHRAC, Mr. Sok Sam Oeun, Chairman of CHRAC/Executive Director of CDP, Tel: (+855) 012 901 199
CHRAC, Mr. Suon Bunsak, Executive Secretary of CHRAC, (+855) 092 344 357
CCIM, Mr. Pa Ngounteang, Executive Director, Email: pnteang@vodhotnews.com, Phone (+855) 060 409 999

អង្គការតម្លាភាពកម្ពុជា សម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម (CISA) មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមន៍ការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) អំពាវនាវដល់រដ្ឋាភិបាលសូមធ្វើការផ្តល់ហេតុផលបន្ថែមលើសេចក្តីសម្រេចដំឡើងតំណែង លោក ឡៅ សារឿន និងជូនដំណឹងដល់សាធារណៈជនថាតើ លោក ឡៅ សារឿន ត្រូវបានរួចផុតពីការចោទប្រកាន់ទាំងឡាយដែរឬទេ។

ដើម្បីប្រកាន់ខ្ជាប់នូវគោលការជាស្ថាប័នប្រឆាំងអំពើពុករលួយឯករាជ្យមួយ អង្គភាពប្រឆាំងអំពើពុករលួយគួរបង្ហាញលទ្ធផលនៃការស៊ើបអង្កេតរបស់ខ្លួន ដើម្បីទទួលបានសេចក្តីទុកចិត្តពីប្រជាពលរដ្ឋក៏ដូចជាលើកកម្ពស់កេរ្តិ៍ឈ្មោះស្ថាប័នផងដែរ។

សម្ព័ន្ធអង្គការសង្គមស៊ីវិលយល់ឃើញថា "ថ្វីត្បិតតែ ទូរគមនាគមន៍កម្ពុជាត្រូវការបន្តដំណើរការងារក្រោមការដឹកនាំរបស់មន្ត្រីថ្មី ដែលទើបត្រូវបានតែងតាំងសម្រាប់តំណែងអគ្គនាយកដើម្បីរៀបចំកិច្ចការឲ្យមានស្ថិរភាពឡើងវិញក្តី សម្ព័ន្ធអង្គការសង្គមស៊ីវិលសូមអំពាវនាវដល់រដ្ឋាភិបាលអោយព្យួរតួនាទីជនជាប់សង្ស័យសិន រហូតដល់ការចោទប្រកាន់ទាំងឡាយលើរូប លោក ឡៅ សារឿន ត្រូវបានបង្ហាញលទ្ធផលស៊ើបអង្កេតពីអង្គភាពប្រឆាំងអំពើពុករលួយ។ ការបង្ហាញគោលការណ៍តម្លាភាពក្នុងការដោះស្រាយករណីបែបនេះ នឹងបញ្ជាក់ថារដ្ឋាភិបាលមានការប្តេជ្ញាចិត្ត និងការទទួលខុសត្រូវក្នុងការប្រយុទ្ធប្រឆាំងការប្រព្រឹត្តិអំពើពុករលួយ"។

**Contact:**
Transparency International Cambodia, Mr Kol PREAP, Email: kolpreap@ticambodia.org, Phone (+855) 012 877 833
CISA, Mr. Yong Kim Eng, Vice Chair Email: cisacoordinator@saatsaam.info, Phone (+855) 016 828 211
CHRAC, Mr. Sok Sam Oeun, Chairman of CHRAC/Executive Director of CDP, Tel: (+855) 012 901 199
CHRAC, Mr. Suon Bunsak, Executive Secretary of CHRAC, (+855) 092 344 357
CCIM, Mr. Pa Ngounteang, Executive Director, Email: pnteang@vodhotnews.com, Phone (+855) 060 409 999